**ខែធ្នូ ឆ្នាំ២០០៦**

មេឃត្រជាក់ដល់ឆ្អឹង....មិនចម្លែកទេព្រោះនេះជាខែរងា។

....វាប្រាកដណាស់ ថាយុវវ័យដែលគ្មានគូនឹងកណ្ដោចកណ្ដែងបំផុតនៅក្នុងខែនេះ.....ប៉ុន្តែ....មិនមែនទាំងអស់ទេ....

....ស្នូរដង្ហើមដង្ហក់ៗលាន់ចេញយឺតៗ....តិចៗ...ពីឃ្លាំងសម្ភារៈចាស់ៗដ៏ធំមួយរបស់សាកលវិទ្យាល័យ....

....សម្រាប់មនុស្សពេញវ័យ...គេដឹងថានេះជាស្នូរនៃការវេញត្របាញ់ចូលគ្នារវាងរាងកាយពីរ។....កណ្ដាលភាពព្រឺព្រួចនៃខ្យល់រាត្រី....គឺគ្មានអ្នកណាដឹងពីរឿងពួកគេទេ។...នារីនិស្សិតនោះអាងលើភាពងងឹតគ្មានពន្លឺសូម្បីតែមួយសរសៃ ដូច្នេះនាងហ៊ានទទួលការថ្នាក់ថ្នមនិងតម្រេករោលរាលរបស់និស្សិតប្រុសម្នាក់។ នាងមិនគិតថាមាននរណាបានឃើញទាំងអស់ ព្រោះសូម្បីតែនាងក៏មិនបានឃើញមុខគូស្នេហ៍នាងដែរ តែនាងបានថតរូបគេជាប់ក្នុងបេះដូងទៅហើយ។ បបូរមាត់គេបានផ្លាស់ប្ដូរមួយផ្នែកទៅសម្ងាត់ៗលើរាងកាយនាង នាងមិនដឹងទេថាមានអ្វីកើតឡើងនៅថ្ងៃស្អែក ហើយក៏មិនដឹងថាអ្នកណាខ្លះកំពុងស្វែងរកពីរនាក់គេពេញបរិវេណមហាវិទ្យាល័យ នាងដឹងតែម្យ៉ាងថានាងពេញចិត្តនឹងក្លាយជារបស់គេ ហើយគេក៏ក្លាយជារបស់នាង។

«សិទ្ធិ! កុំទៅចោលអូនណ៎ា គឺអូនខ្លាច!»

.......

**ខែ មីនា ឆ្នាំ២០០៧**

ហាងតែគជ់ «សាងស្នេហ៍» ជាហាងដ៏ពេញនិយមសម្រាប់ពួកនិស្សិត ព្រោះវាមានចម្ងាយមិនដល់១០០ម៉ែត្រពីរបងសាលាទេ។

«មួយរយៈនេះមានរឿងរិលមុខ! យើងខានមកទីនេះយូរហើយហ្ន៎»

និស្សិតស្រីស្អាតបំផុតប្រចាំដេប៉ាតឺម៉ង់គីមីវិទ្យានិយាយទាំងញញឹមបញ្ចេញស្នាមខួចលើថ្ពាល់ឆ្វេង។

«តែបើយើងមកញឹកពេកប្រាកដជាក្លាយជាប្រធានបទគេនិយាយដើមហើយ»

សិទ្ធិ និស្សិតប្រុសស្រស់សង្ហា ជាខ្សែប្រយុទ្ធក្រុមជម្រើសបាល់ទាត់របស់សាលាឆ្លើយតប ហើយភ្នែកគេក្រឡេកមើលនាងនឹងបង្អួសមកដើមទ្រូងដ៏សិចស៊ីពីក្រោមអាវផ្ទៃមេឃដ៏រឹបរាងរបស់នាង។

«ខ្ញុំម៉ានីយ៉ា! អត់ធ្លាប់ខ្វល់ពីអ្នកផងស្រាប់ទៅហើយ! ពួកគេអស់នោះមិនបានចេញលុយថ្លៃកាហ្វេឱ្យយើងឯណា! និយាយអីនិយាយតាមចិត្ត!»

ស្រីស្អាតក្រឡេកមើលមាត់ទ្វារ ហើយបានសួរបន្ថែម៖

«អី ហើយចុះឯណាតារា មួយរយៈនេះទៅណាមិនហៅតារាផងទេ?»

សិទ្ធិឆ្លើយធ្វើហី៖

«វានឹងមក បើដឹងថាអាយ៉ាងឯងនៅនេះដែរ!»

«ចុះមិនប្រាប់ឱ្យមក!?»

«អត់ចង់!»

«ស្អីគេនៀក! ខឹងគ្នាហ្មង!»

សិទ្ធិនៅស្ងៀមចុចទូរសព្ទទាំងទឹកមុខស្មើ។ ម៉ានីយ៉ាញញឹមសួរ៖

«ប្រុសៗចេះខឹងគ្នាដែរ! ក្រែងមិត្តល្អហ្មេស? តស់ខ្ញុំខលហៅតារាសិន!»

«ចង់ឱ្យវាញ៉ែប្រឹងខលទៅ!»

ម៉ានីយ៉ាសម្លក់ទាំងក្នាញ់ក្នុងពេលសិទ្ធិមិនខ្វីមើលមុខនាង៖

«ស្អីគេ!? មកប្រចណ្ឌទៅរួច!?»

«អត់ជឿ? វាដឹងខ្លួនថាខ្ញុំដឹងរឿងវាលួចស្រលាញ់អាយ៉ាងឯង! វាខ្មាសខ្លួនឯងទេ បានមិនហ៊ានអើតមុខមក!»

ស្រីស្អាតបានចិត្តនិយាយឌឺ៖

«អីស្អាតប៉ុណ្ណឹងដែរ អត់គេស្រលាញ់បានចម្លែក!

សិទ្ធិរអ៊ូព្រោះមិនសប្បាយចិត្តកាន់តែខ្លាំងនឹងពាក្យឌឺនេះ៖

«ថ្ងៃមុនកាលថ្នាក់យើងទៅកំពង់សោមនោះ ចេះតាមទាន់ចំពេលវាលួចទឹកអប់ដែលអាយ៉ាងឯងកាដូឱ្យនោះបាញ់! ដល់ដេញដោលបង្ខំសួរ វាសារភាពថាវាលួចស្រលាញ់អាយ៉ាងឯងមែន ចំមែន ឯងខំទុកចិត្តវា»

ម៉ានីយ៉ាផ្លាស់ទឹកមុខ។ ដំបូងនាងលេងសើចតែដល់សិទ្ធិមើលទៅខឹងមែនទែន នាងក៏រាងពិបាកចិត្តតិចៗ។ រវាងមិត្តជិតដិតបីនាក់ សុខៗក្លាយជាអ៊ីចឹងមានអ្នកណាអរទៅ?

«បានហើយ! កុំធ្វើមុខចឹងមើល៍! ចាំអូនទិញឱ្យមួយដបទៀត ហើយចាំមានពេលនិយាយនឹងតារាឱ្យច្បាស់លាស់រឿងហ្នឹង!»

«មិនបាច់ទេ!» សិទ្ធិនិយាយកាត់ដោយដកដង្ហើមធំហើយលែងទូរសព្ទ ងាកមកក្រេបទឹកភេសជ្ជៈរបស់គេ។

«ថី? និយាយគ្នាទៅគេស្ដាប់បានទេតើ! គេស្រលាញ់ខ្ញុំមានអីខុស? យើងមិនស្រលាញ់គេក៏រាប់អានគេបានទេតើ!»

«វាសម្រេចចិត្តចេញពីមហាវិទ្យាល័យនេះហើយ! គឺទៅរៀនកន្លែងផ្សេង!»
ស្រីស្អាតបើកភ្នែកមូលក្លុំ។
«ម៉េច???? ស្តាយ?»
«កុំមកនិយាយលេងណ៎ា!? រឿងប៉ុណ្ណឹងសោះចាំបាច់អីគេធ្វើដល់ម្លឹង! ហើយមិនឃាត់គេផងទៅ?»
«គឺវាខ្លួនឯងចង់ឃ្លាតពីពួកយើង! បានព្យាយាមលើកទឹកចិត្តវាហើយ ប៉ុន្តែវាគឺមានបំណងចង់ចាកចេញប្រាកដប្រជា វាថាវាមិនចង់ឱ្យពួកយើងពិបាកដោយសារវា ហើយវាត្រូវការបំភ្លេចនាងផងម៉ានីយ៉ា! វាថាពេលឃើញនាងរាល់ថ្ងៃ វាពិបាកធ្វើចិត្តណាស់! អើ! មិនដឹងធ្វើម៉េចដែរតាមតែវាទៅ!»

ម៉ានីយ៉ានៅស្ងៀមដោយក្រៀមក្រំ នាងផ្អែកខ្នងទៅនឹងសាឡុងព្រោះនឹកអាណិតមិត្ត។ យល់ចិត្តនាង សិទ្ធិលូកដៃមកច្បួតច្រមុះស្រីម្ចាស់ស្នេហ៍លេងៗ៖
«មកពីយើងហ្នឹង! ដឹងអត់?»
«តាវានេះឆ្កួតមែនហ្មង!»

នាងរអ៊ូតិចៗតែចិត្តអាណិតគេយ៉ាងក្តុកក្តួល។

.......

**ខែវិច្ឆិកា ឆ្នាំ២០១៣**

....សភាពខ្មៀវខ្វារដោយការជជែកគ្នារបស់ភ្ញៀវបានរលត់បាត់បន្តិចម្តងៗ ជំនួសមកវិញដោយសំឡេងខ្សឹបខ្សៀវក្នុងពេលដែលរថយន្តលេនរ៉ូវើពណ៌សក្បុសមួយបោលមកដល់នាំមកជាមួយនូវវត្តមានទេពអប្សរស្រស់ស្អាតក្នុងឈុតរាត្រីសមោសរ ម៉ូដែលពណ៌ទឹកមាសភ្លឺព្រាតហើយវែងអូសដី។
«ម៉ានីយ៉ា?»
«គេហ្នឹងជាម៉ានីយ៉ាមែនអត់រ៉ឺ? គេស្អាតម៉េះ? ឡូយណាស់ហ្ន៎?»
«ត្រូវហើយ! គេគឺម៉ានីយ៉ា!»

សំឡេងខ្សឹបខ្សៀវមិនបានបង្អាក់អារម្មណ៍រីករាយស្រស់ថ្លារបស់ម៉ានីយ៉ាធីតាអភិជនទេ។ នាងញញឹមបង្ហាញថ្ពាល់រលោងក្រពុំពោរពេញដោយមន្តស្នេហ៍តបទៅកាន់ក្រសែភ្នែកមិត្តរួមសាលាទាំងឡាយដែលបោះបង់ចោលការជជែកហើយបែរមករកនាង។
«អបអរសាទរតារាសម្រាប់ការទទួលបានតំណែងរដ្ឋលេខាធិការ!»

ម៉ានីយ៉ានិយាយទៅកាន់បុរសសម្បុរស ខ្ពស់ ដែលកាលពីមុនជាមិត្តជិតដិតរបស់នាងនៅមហាវិទ្យាល័យ។ គេដើរមកទទួលនាង ព្រមពេលនាងលើកកន្ត្រកផ្កាពីដៃសូហ្វ៊ែរឡានហើយហុចទៅឱ្យគេ។

ម្ចាស់ខ្លួន គឺតារាមិនទាន់បានថាតបយ៉ាងណាផងស្រាប់តែសំឡេងមួយលាន់មកពីក្នុងចំណោមមិត្តចាស់៖

«ម៉ានីយ៉ា! ឯងហៅគេថាឯកឧត្តមតែម្ដងទៅវ៉ី»

៧ឆ្នាំហើយដែលពួកគេបែកគ្នា។ គេមិនដែលសូម្បីតែចួបមុខ។ ពេលនេះមិត្តចាស់វិលមកវិញម៉ានីយ៉ាគឺវ័យម្ទេក្រាស់ឯគេក៏សាមស្ដើងទៅហើយ។ វ័យជំទង់រំលងទៅ តើស្នេហារបស់គេចំពោះនាងនៅដូចដើមឬយ៉ាងណា? នេះជាអ្វីដែលគ្រប់គ្នានៅទីនេះកំពុងគិតនិងតាមមើលប្រុសស្រីទាំងទ្វេ តែម៉ានីយ៉ាគ្មានពេលគិតពីអតីតកាលនោះឡើយ បើតាមទឹកមុខស្រស់ថ្លាឥតកង្វល់របស់នាងក្នុងពេលនេះ។

ម៉ានីយ៉ាញញឹម នាងងាកទៅរកមិត្តភក្ដិហើយនិយាយទាំងខ្ទប់មាត់សើច៖

«អូមែន! គឺអបអរសាទរឯកឧត្តម!»

តារាញញឹមញញែម។

«អាយ៉ា! ស្មានតែឯងអត់បានមកទេពួកម៉ាក!»

«អីគេ! ពួកម៉ាកឡើងឯកឧត្តមទាំងមូលអត់មកបានដែរ?»

អ្នកទាំងពីរគឺជាមិត្តល្អហើយជិតស្និទ្ធបំផុត....ដែលអ្នកផងដឹងឮ ប៉ុន្តែមិនទាន់ចប់ទេ គឺនៅមានអ្នកទីបីម្នាក់ទៀត។

«ហ្នាពូគីង្គក់! អត់ទាន់មកដល់ទៀត?» នាងសួរទាំងសម្លឹងតារារង់ចាំចម្លើយ។ តារាដឹងហើយថា «ពូគីង្គក់» ជាមនុស្សដែលម៉ានីយ៉ាចង់រកជាងគេនៅក្នុងពិធីយប់នេះ។

«វា.....»

មិនទាន់បញ្ចប់ប្រយោគផង ស្នូរឡានឈប់ង៉ឹតដាស់អ្នកទាំងអស់ឱ្យងាកទៅរកព្រំក្រហមដែលបង្ហាញវត្តមានមនុស្សបីនាក់ត្រូវបានសូហ្វ័របើកទ្វារឱ្យចុះពីលើរថយន្តទំនើបពណ៌ខ្មៅរលើប។

«សិទ្ធ?!»

តារារបូតមាត់ដោយអំណរ ធ្វើឱ្យបេះដូងម៉ានីយ៉ាលោតខុសសង្វាក់។ នាងរវេភ្នែកទៅរកមនុស្សបីនាក់ដែលកំពុងឈានដើរលើព្រំក្រហមសំដៅមក។ នោះគឺស្ត្រីវ័យចំណាស់ក្នុងឫកពាជាអភិជនអមដំណើរសងខាងដោយបុរសសង្ហាម្នាក់ទុកពុកចង្ការឹមៗហើយញញឹមសម្លឹងមកគ្រប់គ្នាដោយរួសរាយ។

....គេបានបញ្ឈប់ភ្នែកត្រឹមនាង....ក្នុងពេលពុកចង្កាគេបានដាស់នាងឱ្យព្រឺព្រួចនឹកដល់ល្បែងស្នេហ៍កាលវ័យជំទង់នាយប់ខែកត្តិកក្នុងឃ្លាំងមហាវិទ្យាល័យដ៏ព្រឺព្រួច។ នាងព្រឺសម្បុរហើយឈាមរត់បញ្ច្រាសបញ្ចេញភាពក្រហមព្រឿងៗលើផ្ទៃមុខ។

«ពូគីង្គក់មកហើយ មីងកង្កែបសប្បាយចិត្តឬនៅ?»

តារាខ្សឹបតិចៗឌឹដងឱ្យម៉ានីយ៉ាហើយត្រៀមលក្ខណៈគេចពីការក្តិចគ្រីតរបស់នាង តែលើកនេះនាងនៅភ្លឹកមិនខ្វល់នឹងពាក្យឡកឡឺយឡើយ ព្រោះនាងកំពុងជំពាក់ស្នាមញញឹមជាមួយបុរសដែលទើបនឹងមកដល់។

«សិទ្ធ!» នាងនិយាយតិចៗក្នុងបេះដូង តែមិនបណ្តោយឱ្យឈ្មោះគេនឹងភាសាហៅដ៏ផ្អែមរបស់នាងលាន់ឮចេញមកក្រៅឡើយ ប៉ុន្តែភាគីខាងប្រុសបានហៅនាងស្រាលៗ៖

«អាយ៉ា!»

សំឡេងគេធ្វើឱ្យស្ត្រីចំណាស់ដែលនៅកណ្តាលនិងបងស្រីរបស់គេដែលដើរអមដៃរនោះរេភ្នែកមករកនារីអាវពណ៌មាសព្រមៗគ្នា។

ម៉ានីយ៉ាលើកដៃជម្រាបសួរទាំងអៀនអន់។ ម្រាមដៃនិងគ្រឿងអលង្ការនាងបង្ហាញស្ត្រីចំណាស់និងស្ត្រីវ័យកណ្តាលទាំងទ្វេហើយជាស្រេចថានារីដែលអ្នកប្រុសសិទ្ធិចាប់អារម្មណ៍ មិនមែនមកពីគ្រួសារធម្មតាឡើយ។

«លើកដៃថ្វាយព្រះកូន! កូនយ៉ាធំយ៉ាងនេះហើយ?»

ម្តាយអ្នកប្រុសសិទ្ធិនិយាយតិចៗតាមស្ទីលស្ត្រីអ្នករបៀប។

«លោកប៉ាអត់អញ្ជើញមកទេសិទ្ធិ?»

សំឡេងមួយសួរមកពីក្នុងចំណោមមិត្តក្នុងពេលតារាម្ចាស់ពិធីកំពុងឱនគោរពអ្នកស្រីទិវាជាម្តាយនិងបងស្រីរបស់សិទ្ធិ។

សិទ្ធិប្រែប្រួលស្នាមញញឹមតែគេខំឆ្លើយវិញ៖

«លោកមានធុរៈ!»

តារារេភ្នែកសម្លឹងម៉ានីយ៉ាចំពេលនាងមើលមកដោយពិបាកចិត្តដូចគ្នា។ មានតែអ្នកទាំងពីរទេដែលដឹងថាប៉ារបស់សិទ្ធិមានជំងឺសរសៃប្រសាទដែលមិនអាចចេញមកចូបភ្ញៀវពន្លឺបានឡើយ។ បន្ទាប់មកតារានិងម៉ានីយ៉ាក៏ងាកមកមើលមុខបងស្រីរបស់សិទ្ធិទៀត ព្រោះគេទាំងពីរដឹងទៀតដែរថាសិទ្ធិក៏មិនងាយនាំបងគេមកចំណោមមនុស្សដែរ ព្រោះនាងជាមនុស្សធ្មឹងៗមិនចេះនិយាយស្តីមាននិស្ស័យខុសប្លែកគេឯង។

យប់នេះគេនាំក្រុមគ្រួសារមកដល់ទៅបីនាក់ គឺបញ្ជាក់ពីការរាប់អានជិតស្និទ្ធជាមួយតារាម្ចាស់ពិធីហើយ។

«អ្នកម៉ាក់អញ្ជើញមកខាងណេះ ចួបអ្នកម៉ាក់របស់តារាណា៎!»

គេនិយាយជាមួយម្តាយដើម្បីបំបាត់ចោលបរិយាកាសដែលគេមិនចង់បន្ត។ ម៉ានីយ៉ាដឹងរឿង

នេះ នាងបានជួយគេបន្ថែមថា៖
«អញ្ជើញខាងណោះអ្នកអ៊ំ!»
មិត្តភក្តិរបស់សិទ្ធិទាំងឡាយយល់ថា នេះជាឱកាសល្អរបស់សិទ្ធិក្នុងការកសាងទំនាក់ទំនងរវាងម្ដាយគេនិងម៉ានីយ៉ាហើយ។
មិនខុសមែន គេឆ្លៀតពេលនេះនិយាយដោយស្រទន់ទៅកាន់ស្រីស្អាត៖
«អរគុណអាយ៉ា!»
អ្នកស្រីទិវាម្ដាយសិទ្ធិត្រូវបានស្រីស្អាតនាំទៅចូបរាក់ទាក់ជាមួយភ្ញៀវស្រីៗដែលភាគច្រើនមកពីសង្គមជាន់ខ្ពស់ដូចគ្នា ធ្វើឱ្យស្ត្រីនោះសប្បាយរីកមុខមាត់នឹងភ្លេចខ្លួនទុកចោលកូនស្រីច្បងមិនសូវគ្រប់ទឹកឱ្យឈររេរាម្នាក់ឯង។
ដំបូងម៉ានីយ៉ាបានចូលទៅក្បែរនាំអនាគតបងថ្លៃស្រីមិនគ្រប់ទឹកនោះឱ្យជជែកលេង ញ៉ាំនេះនោះដែរ តែក្រោយមកមិត្តចាស់មកកាន់តែច្រើនការជជែកលេងសើចនិងរំលឹកអតីតកាលបានធ្វើឱ្យនាងសន្សឹមៗភ្លេចបងស្រីរបស់សិទ្ធិឱ្យនៅហេងហាងម្នាក់ឯងកណ្ដាលពិធី។
ក្នុងពេលសិទ្ធិកំពុងជាប់ជជែកជាមួយក្រុមបុរសៗ! ដោយគិតថាបងស្រីនិងម្ដាយគេត្រូវបានស្រីស្រស់ម៉ានីយ៉ាទទួលរាក់ទាក់កសាងទំនាក់ទំនងនោះ បងស្រីគេគឺអ្នកនាងធំ វ៉ានីន ដែលមានចរិតមិនគ្រប់ដប់តាំងពីកំណើតបានឈរដោយអឹមអៀននិងមិនដឹងត្រូវទំនាក់ទំនងជាមួយអ្នកផងជុំវិញខ្លួនដោយរបៀបណាឡើយ។
ភ្លាមៗនោះនាងមានអារម្មណ៍ថាវង្វេងពីប្អូនប្រុសនិងម្ដាយ។
នាងវេភ្នែករកមើលពួកគេដោយតក់ក្រហល់និងអន្ទះសាដូចកូនក្មេងមិនដឹងក្ដី។
នាងងើបមុខសម្លឹងគេហដ្ឋាននោះ ស្រាប់តែនៅជាន់ទីមួយ លេចចេញរូបម្ដាយនាងបង្ហាញខ្លួននៅខាងមុខយ៉បន្ទប់ហើយបក់ដៃហៅនាង។
«អូ? អ្នកម៉ាក់ឡើងទៅទីនោះពីអង្កាល់?»
នាងងាកជុំវិញខ្លួនរកប្រាប់សិទ្ធិតែមិនឃើញនាយសោះ នាងក៏សម្រេចចិត្តរត់ទៅក្នុងផ្ទះឡើងទៅតាមម្ដាយហៅ។
«ឡើងមកកូន! វ៉ានីន! ឡើងមក»
សំឡេងម្ដាយនាងនាំមកពីជាន់ខាងលើពេលនាងដើរមកដល់បន្ទប់សាឡុងក្នុងផ្ទះម្ចាស់កម្មវិធីដែលគ្មានមនុស្សនៅម្នាក់ឡើយ។
«ម៉ាក់?» នាងគិតក្នុងចិត្តតែនៅមិននិយាយអ្វីតាមធម្មជាតិដែលមិនងាយគ្រលាស់អណ្ដាតចេញ។ តែនាងបានរត់ឡើងទៅជាន់លើតាមជណ្ដើរយ៉ាងលឿនព្រោះក្នុងកាលៈទេសៈមិនសប្បាយចិត្តនិង

ចម្លែកដូច្នេះ នាងចង់នៅជិតម្ដាយបំផុត។
«ប្រហែលអ្នកម៉ាក់ក៏ធុញពិធីនេះដូចគ្នាបានជាគាត់ឡើងទៅសម្ងំនៅខាងលើហើយហៅខ្ញុំទៅ!» នាងគិតដូច្នេះ។

នៅឯណេះសិទ្ធិបង្អង់ពីការរាក់ទាក់របស់មិត្តចាស់។

គេដៀងភ្នែកមករកម្ដាយនិងបងស្រីក៏ឃើញស្រីស្អាតម៉ានីយ៉ានៅតែម្នាក់ឯង។ ដំបូងគឺគេចាប់អារម្មណ៍រកម្ដាយនិងបង តែនាងដើរសំដៅមកធ្វើឱ្យគេចាំបាច់ត្រូវរាក់ទាក់ស្រីស្អាត៖
«សុខសប្បាយទេ?»
«ធម្មតា! ចុះសិទ្ធិវិញ?» ម៉ានីយ៉ាដៀងភ្នែកសម្លឹងមុខនាយធ្វើឱ្យចៃដន្យភ្នែកនិងភ្នែកប៉ះគ្នាបង្កើតទៅជាកម្លាំងប្រទាក់មួយរវាងអតីតសង្សារកាលនៅរៀនដែលអ្នកណាៗក្នុងយប់នេះសុទ្ធតែដឹងថាពីរនាក់គេធ្លាប់ជាសង្សារ។

មិនដឹងយ៉ាងម៉េច៧ឆ្នាំហើយ គេបែកគ្នាធ្វើឱ្យម្នាក់ៗចួបគ្នាវិញនិយាយស្ដីគួរសម លែងឌឺដងគ្រោតគ្រាតដូចមុន តែស្នេហាមួយនោះម៉ានីយ៉ាមិនងាយបំភ្លេចបានឡើយ។ ភាគីខាងប្រុសប្រហែលជាដូចគ្នា ពិសេសគឺហេតុការណ៍នៅឯឃ្លាំងមហាវិទ្យាល័យដែលជាការផ្សារភ្ជាប់រាងកាយជាដំបូងក្នុងជីវិតរបស់ពួកគេ។

ពេលវេលាស្ងាត់ស្ងៀមបន្លាយបានបន្តិច សិទ្ធិដឹងអារម្មណ៍មកវិញមុនគេធ្វើជានិយាយតិចៗ៖
«អាយ៉ាឯងស្អាតម៉េះ?»

ស្រីស្អាតកាន់តែរំភើបរកតបពាក្យវិញមិនបាន។
«មានរឿងមួយចង់និយាយប្រាប់អាយ៉ាឯង!.....តែនិយាយនៅទីនេះមិនកើតទេ!»

នាងមិនចោលស្នាមញញឹមនៅមុខបុរសដែលនាងបានប្រគល់បេះដូងនិងភាពបរិសុទ្ធនោះឡើយ។ ម៉ានីយ៉ាបើកភ្នែកក្រឡង់បង្អួតពន្លឺថ្លាយង់ ហើយសួរ៖
«រឿងអីអាថ៌កំបាំងម៉េះសិទ្ធិ?»
«ស្អែកចួបគ្នានៅកន្លែងណាមួយបានអត់? អ្ហះយ៉ា? ស្អែកល្ងាចម៉ោង៦ អូខេ?»
«បានតើ!» នាងអឹមអៀន តាមពិតនាងក៏ចង់ចួបគេជាខ្លាំងដែរ។
«OK នៅកន្លែងចាស់របស់យើង!» សិទ្ធិនិយាយទាំងសប្បាយចិត្តរីកបេះដូងប៉ុនចង្អេរ។

នាងមិនឆ្លើយតែងក់ក្បាលតិចៗ។

កន្ទុយភ្នែករំកិលមកថាម្ដាយកំពុងតែសសៀរមកជិតពួកគេ សិទ្ធិចាប់ផ្ដើមបន្តនិយាយទៅកាន់ស្រីស្នេហ៍៖
«កុំភ្លេចណា៎!»

គេញញឹមនិងឱ្យពន្លឺភ្នែកពោរពេញដោយភាពស្រទោស្រទន់អាណិតស្រលាញ់មកកាន់នាងជាចុងក្រោយមុនពេលបង្វែរកាយដើរទៅរកម្ដាយ។

«អ្នកម៉ាក់?»

អ្នកស្រីនោះប្រកបដោយទឹកមុខភិតភ័យៈ

«សិទ្ធិ! បាត់បងស្រីកូនហើយ!»

សិទ្ធិថ្លោះទឹកមុខ។

គេក្រឡេករកមើលវ៉ានីនរឹង។ នៅជុំវិញពិធីមិនឃើញស្រមោលនាងសោះ។

«គាត់ទៅណាលឿនម៉េះ! ចំមែនហើយខ្ញុំ!»

គេបន្ទោសខ្លួនឯងតិចៗដោយមិនដឹងទេថានៅឯណោះវ៉ានីនបានឡើងមកដល់ជាន់ទី១ស្រេចទៅហើយ។

ជាន់នោះស្ងាត់ជ្រងំសឹងថាស្ងាត់ជាងនៅឯជាន់ខាងក្រោមទៅទៀត គឺបរិយាកាសមានតែសូរភ្លេងពីខាងក្រោម ឯពិធីនោះលាន់មកល្វើយៗ។

តែនៅឯណោះ....គ្មានមនុស្សសូម្បីតែម្នាក់។

«ម៉ាក់ៗ» នាងគិតក្នុងចិត្ត តែអណ្ដាតនាងគ្រលាស់មិនចេញឡើយ។ ដូចមានអ្នកណាម្នាក់ដើរកាត់រឹងពីក្រោយខ្នង ធ្វើឱ្យនាងបែរក្រោយទៅរកមើល។ គ្មានឃើញអ្នកណាសោះឃើញតែទ្វារបន្ទប់មួយក្នុងចំណោមទ្វារជាច្រើនកម្រើកតិចៗ ហាក់ដូចមានអ្នកណាម្នាក់ទើបតែចូលទៅ។

ដោយមិនសង្ស័យអ្វីទេ នាងវ៉ានីនអន្ទះសាចូលទៅកាន់ទីនោះព្រោះថានាងកាន់តែខ្លាចនាងកាន់តែចង់ឱបម្ដាយនាង។ នាងមកដល់មាត់ទ្វារនោះជាស្រេចដោយឮសំឡេងតិចៗពីខាងក្នុង

«ចូលមកវ៉ានីន!»

នាងដាក់កែវទឹកក្រូចនៅលើដៃទៅលើជើងផ្កាមួយធំនៅមាត់ទ្វារបន្ទប់នោះ។ ឈានចូលទៅភ្លាម តែបន្ទប់ងងឹតពេក....គឺងងឹតដល់ថ្នាក់មើលអីមិនឃើញតែត្រឹមប៉ុន្មានជំហានខាងមុខនាង។ ពេលនាង ចូលបានពីរជំហាន ទ្វារបិទទៅវិញគ្រឹបដោយឯកឯង។

វ៉ានីននាងភ័យញ័រ ព្រោះមានស្មារតីមិនរឹងមាំដូចអ្នកដទៃ។ នាងចង់ស្រែកហៅម្ដាយ បន្ទាប់មកស្រែកហៅបងប្រុសនៅខាងក្រោមទៀតព្រោះតែភ័យពេក តែស្រែកក៏មិនចេញ។